ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ ៣ កក្កដា - កញ្ញា ឆ្នាំ២០០៩ តម្លៃ ១.៥០០រ

## ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលើប្រជាជនក្រីក្រ និង ជនងាយរងគ្រោះក្នុងប្រទេសកម្ពុជា*

ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចសាកលកំពុងវិវត្តបន្តទៀតក្នុងពេលបច្ចុប្បន្ន ។ទោះបីសេណារីយ៉ូមហាវិនាស ដែលគេប្រមើលឃើញពីដំបូងមិនបានកើតមានជាក់ស្តែង ហើយក៏ប្រហែលមិនកើតមានទេ ក្នុងមួយរយៈពេលខាងមុខដែលគេអាចមើលឃើញ ប៉ុន្តែមកទល់ពេលនេះ វិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរណាស់ទៅហើយលើជីវភាពរបស់គ្រួសារក្រីក្រ និងជនងាយរងគ្រោះនៅគ្រប់ទិសទី រួមទាំងប្រទេសកម្ពុជាផងដែរ ។ នៅកម្ពុជា ផលប៉ះពាល់វាស្តែងឡើង តាមរយៈការជះឥទ្ធិពលអាក្រក់ទៅលើបណ្តាសកម្មភាពសេដ្ឋកិច្ចស្នូល ដូចជា វិស័យកាត់ដេរ សាងសង់ និងទេសចរណ៍ ។ ដោយឡែក វិស័យកសិកម្មហាក់ដូចជាមិនរងផលប៉ះពាល់ធ្ងន់ធ្ងរទេ ព្រោះមានកំណើនល្អគួរសមក្នុងអំឡុងពេលនេះ ។

ឫសគល់នៃវិបត្តិនេះ គឺវិបត្តិហិរញ្ញវត្ថុដែលផ្តើមចេញពីសហរដ្ឋអាមេរិក ដោយមានការពិភាក្សាវែកញែកជាច្រើនថា តើវាបានចាប់ផ្តើមនៅពេលណា ។ ក្របខ័ណ្ឌច្បាប់ធូររលុងនៅសហរដ្ឋអាមេរិក និងប្រទេសផ្សេងៗទៀត គួបផ្សំបណ្តាញពឹងផ្អែកគ្នាចុះឡើង រវាងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ បានធ្វើឱ្យវិបត្តិហិរញ្ញវត្ថុអាមេរិកនេះ ក្លាយទៅជាវិបត្តិហិរញ្ញវត្ថុសាកល ហើយក៏វិវត្តទៅជាវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរក្នុងរយៈពេលយ៉ាងខ្លី ។ ការរីករាលដាល នៃវិបត្តិហិរញ្ញវត្ថុវាប្រែប្រួលទៅតាមទំហំនៃការចូលរួមរបស់ប្រទេសនីមួយៗ នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ។ ប្រទេសណាមានការពាក់ព័ន្ធតិចតួច ឬគ្មានសោះ ពុំមានការប៉ះពាល់ធ្ងន់ធ្ងរទេ ។ ទោះជាយ៉ាងនេះក្តី តែក្នុងមួយរយៈពេលខ្លីសោះ វិបត្តិហិរញ្ញវត្ថុបានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចក្នុងប្រទេសជាច្រើន ដែលធ្វើឱ្យធ្លាក់ចុះពាណិជ្ជកម្មអន្តរជាតិ និងលំហូរមូលធនអន្តរជាតិ ជាពិសេសវិនិយោគផ្ទាល់ពីបរទេស (FDI) និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស (ODA) ។ ដោយសារប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ជាច្រើនមានការពាក់ព័ន្ធ និងពឹងផ្អែកយ៉ាងខ្លាំង ទៅលើពាណិជ្ជកម្មអន្តរជាតិ FDI និង ODA ដូច្នេះផលប៉ះពាល់ទៅលើសេដ្ឋកិច្ច ក៏កាន់តែធ្ងន់ធ្ងរឡើង ។ សំរាប់ករណីដូចជានៅប្រទេសកម្ពុជា ដែលមានជាង ៨០% នៃប្រាក់ចំណូលលើការនាំចេញបានពីផលិតផលកាត់ដេរ ដូច្នេះការថយចុះក្នុងពាណិជ្ជកម្មផលិតផលកាត់ដេរនឹងប៉ះពាល់ធ្ងន់ធ្ងរដល់សកម្មភាពសេដ្ឋកិច្ចជាទូទៅ ជាពិសេស ផលិតកម្ម

(តទៅទំព័រ ៥)



*ឥទ្ធិពលមួយនៃវិបត្តិសេដ្ឋកិច្ចនាបច្ចុប្បន្ន: មានអ្នកជិះស៊ីក្លូ និងម៉ូតូឌុបតិចតួចប៉ុណ្ណោះ នៅទីក្រុងភ្នំពេញ*

* Hossein Jalilian នាយកផ្នែកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ណែនាំបង្ហាញពីទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា លេខពិសេសនេះ ដែលផ្តោតលើផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចសាកល ទៅលើគ្រួសារក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា។

## មាតិកា

ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលើប្រជាជនក្រីក្រ និង ជនងាយរងគ្រោះក្នុងប្រទេសកម្ពុជា ........................ ១
អង្កេតលើកម្មករងាយរងគ្រោះនៅ រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ សៀមរាប និង បាត់ដំបង ........................................ ២
ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃ វិបត្តិសេដ្ឋកិច្ចសាកល ទៅលើគ្រួសារនៅកម្ពុជា: ឥទ្ធិពល និង យុទ្ធសាស្ត្រដោះស្រាយ ... ៦
ការគ្រប់គ្រងមិនផ្លូវការលើហានិភ័យ និងការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គម: បទពិសោធន៍សិក្សាពីគ្រួសារ និង ពលករក្រីក្រ និងងាយរងគ្រោះ ............................................ ១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស........................ ១៦
— ស្ថានភាពក្នុងប្រទេស........................ ១៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ................................ ២៤

# អង្កេតលើកម្មករងាយរងគ្រោះនៅ រាជធានីភ្នំពេញ ខេត្តកណ្ដាល កំពង់ស្ពឺ សៀមរាប និង បាត់ដំបង*

## ១. សេចក្ដីផ្ដើម

អត្ថបទនេះ ព្យាយាមវាយតម្លៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ចនៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើកម្មករងាយរងគ្រោះ នៅប្រទេសកម្ពុជា ។ ក្នុងនេះការសិក្សាបានផ្ដោតជាចំបងលើឥទ្ធិពលនៃវិបត្តិទៅលើ ចំណូលប្រចាំថ្ងៃពិតចំណាយប្រើប្រាស់ប្រចាំថ្ងៃពិត និងការវិវត្តនៅឆ្នាំខាងមុខ ដោយប្រើទិន្នន័យបានពីអង្កេតធ្វើឡើងនៅ ទីក្រុងភ្នំពេញ ខេត្តកណ្ដាល និង កំពង់ស្ពឺ តាំងពីឆ្នាំ២០០៣ និងធ្វើនៅតំបន់ពីរផ្សេងទៀត (ខេត្តសៀមរាប និងបាត់ដំបង) កាលពីខែឧសភា ២០០៩ ព្រមទាំងការពិភាក្សាតាមក្រុមស្នូល ។

កន្លងមកមានការសិក្សាមួយចំនួនតូច បានព្យាយាមវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលទៅលើសេដ្ឋកិច្ចកម្ពុជា នៅកំរិតម៉ាក្រូ កំរិតតាមវិស័យ (កសិកម្ម កាត់ដេរ ទេសចរណ៍ និងសំណង់) ទីផ្សារពលកម្ម និងកំរិតគ្រួសារ ។ ការសិក្សានានាពីការវាយតម្លៃរហ័ស (Kang et al. 2009; Jalilian et al. 2009) ដែលផ្សព្វផ្សាយហើយ បានបង្ហាញថា ផលប៉ះពាល់ខាងម៉ាក្រូសេដ្ឋកិច្ច នឹងរឹតតែធ្ងន់ធ្ងរឡើង ដោយសារការរួមចុះក្នុងវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ។ វិស័យកាត់ដេររងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត គឺពីខែកញ្ញា ២០០៨ ដល់ពាក់កណ្ដាលខែមីនា ២០០៩ មានការបញ្ឈប់កម្មករអស់ ១៤% ក្នុងចំណោមកម្មករសរុប ៣៥០.០០០នាក់ ដោយសារការនាំចេញធ្លាក់ចុះជាខ្លាំង ។ ចំនួនភ្ញៀវទេសចរមកកម្ពុជា បានធ្លាក់ចុះដោយមានអត្រាកំណើនប្រចាំឆ្នាំអវិជ្ជមាន អស់ ៦ខែជាប់ៗគ្នា ចាប់តាំងពីខែតុលា ២០០៨ មក ។ នៅខេត្តសៀមរាបដែលជាកន្លែងទទួលទេសចរសំខាន់បំផុតនៅកម្ពុជា សណ្ឋាគារជាច្រើនទទួលបានអត្រាស្នាក់នៅកំរិតទាបហើយសណ្ឋាគារប្រណីតៗខ្លះ បានបញ្ឈប់ដំណើរការជាបណ្ដោះអាសន្ន ។ បុគ្គលិកនៅតាមសណ្ឋាគារទាំងនោះ ត្រូវឈប់សំរាកដោយគ្មានប្រៀវត្សរ៍ ឬក៏ត្រូវបញ្ឈប់ពីការងារជាបណ្ដោះអាសន្ន ។ អង្គការរូបិយវត្ថុអន្តរជាតិ (IMF) បានគន់គូរថា វិស័យទេសចរណ៍ នឹងធ្លាក់ចុះអស់ ៥% ដោយសារការថយចុះតំរូវការធ្វើដំណើរក្នុងពិភពលោក ។ វិស័យសំណង់ក៏ត្រូវធ្លាក់ចុះ ធ្ងន់ធ្ងរដែរ ពីព្រោះវិនិយោគិនបរទេសក្នុងវិស័យអចលនទ្រព្យ បានកាត់បន្ថយឬពន្យាពេលអនុវត្តគម្រោងធំៗ ដោយសារវិបត្តិឥណទាននៅឯប្រទេសដើមរបស់ពួកគេ ។ ប៉ុន្តែវិស័យកសិកម្មរំពឹងថានឹងមានកំណើនខ្លាំងក្លា ដែលនឹងជួយប៉ះប៉ូវដល់វិស័យដទៃៗទៀតនៃសេដ្ឋកិច្ច ។ Kang (2009) បានរាយការណ៍ពីការធ្លាក់ចុះចំណូលប្រចាំគ្រួសារ បង្កដោយការថយចុះនៃប្រាក់ផ្ញើទៅផ្ទះរបស់កម្មករចំណាកស្រុក ។

ការសិក្សាពីមុនៗ បានព្យាយាមវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលទៅលើសេដ្ឋកិច្ចកម្ពុជា ដោយប្រើប្រាស់ការវិភាគបែបពណ៌នានិងការពិភាក្សាតាមក្រុមស្នូល ។ វិធីសាស្ត្រទាំងនេះទំនងមិនអាចបង្ហាញលទ្ធផលបានច្បាស់លាស់ទេ ដោយសារមានព្រឹត្តិការណ៍មួយចំនួនកើតឡើងដូចជា ការឡើងថ្លៃម្ហូបអាហារ ទំនាស់ព្រំដែនរវាងកម្ពុជា-ថៃ និងការប៉ះទង្គិចដោយឡែកៗមួយចំនួន ដែលកើតមាននៅក្នុងឆ្នាំ២០០៨ ។ ការសិក្សានេះនឹងអនុវត្តបច្ចេកទេសបែបបរិមាណយ៉ាងសាមញ្ញមួយ ដែលអាចប្រើប្រាស់បានយ៉ាងទូលំទូលាយ ដោយសារវាផ្អែកលើអង្កេតធម្មតាៗ ដើម្បីធ្វើការប៉ាន់ស្មានពីផលប៉ះពាល់នៃវិបត្តិទៅលើចំណូល និងចំណាយរបស់បុគ្គល ។

## ២. វិធីសាស្ត្រស្រាវជ្រាវ និង ដែនកំណត់

តាំងពីឆ្នាំ១៩៩៨ មក CDRI បានធ្វើអង្កេតប្រចាំត្រីមាសលើពលករងាយរងគ្រោះចំនួន ៤ក្រុម នៅក្នុងទីក្រុងភ្នំពេញ គឺមាន អ្នកធាក់ស៊ីក្លូ អ្នកលីសែងអ្នកលក់បន្លែតូចតាច និង អ្នករើសអេតចាយ ។ នៅឆ្នាំ២០០០ អង្កេតនេះបានពង្រីកទៅធ្វើលើពលករ ៦ក្រុមផ្សេងទៀត គឺ អ្នករត់ម៉ូតូឌុប កម្មករសំណង់គ្មានជំនាញ កម្មករសំណង់មានជំនាញ អ្នកបំរើតុភោជនីយដ្ឋាន កម្មកររោងចក្រកាត់ដេរ និងអ្នកស៊ីឈ្នួលធ្វើស្រែ (នៅខេត្តកណ្ដាល និងកំពង់ស្ពឺ) ។ គំរូតាងសរុបក្នុងអង្កេត មាន ៤៨០នាក់ ក្នុងនោះ កម្មករកាត់ដេរ មាន ១២០នាក់ និង កម្មករក្នុងក្រុមដទៃៗទៀត មាន ៤០នាក់/ក្រុម ។ នៅខែឧសភា ២០០៩ ដោយមានជំនួយមូលនិធិមួយភាគពីធនាគារពិភពលោក វិទ្យាស្ថាន CDRI បានបញ្ចូលពលករងាយរងគ្រោះ ២ក្រុមទៀត គឺ ពលករចំណាកស្រុក (២០សម្ភាសន៍ នៅខេត្តបាត់ដំបង) និង ពលករខាងទេសចរណ៍ (២០សម្ភាសន៍ នៅខេត្តសៀមរាប) ។ សរុបមក អង្កេតនេះមានប្រើគំរូតាង ចំនួន ៥២០នាក់ ។ ក្រៅពីអង្កេតជាលក្ខណៈរៀបរយ ក៏មានធ្វើការពិភាក្សាតាមក្រុមស្នូលជាមួយនឹងពលករខាងទេសចរណ៍ និង ពលករចំណាកស្រុក ដើម្បីកំណត់ពីផលប៉ះពាល់នៃវិបត្តិទៅលើគ្រួសារនានានៅខេត្តសៀមរាប និងបាត់ដំបង ។ គំរូតាងត្រូវបានជ្រើសរើសដោយមានគោលដៅនៅនឹងកន្លែងផ្ទាល់ ដែលភាគច្រើននៅតាមតំបន់ទីក្រុង ហើយក្នុងនេះមានទាំងពលករស៊ីឈ្នួល និងពលករប្រកបមុខរបរខ្លួនឯង ដូច្នេះលទ្ធផលបានពីការសិក្សានេះ មិនតំណាងឱ្យសកម្មភាពសេដ្ឋកិច្ចនីមួយៗទេ ហើយក៏មិនអាចកំណត់ថា វិស័យសេដ្ឋកិច្ចមួយណា ដែលបានស្រូបយក ពួកកម្មករត្រូវបញ្ឈប់ពីការងារ (ឧ. កម្មករកាត់ដេរ) នោះដែរ ។

ដើម្បីកំណត់ពីផលប៉ះពាល់នៃវិបត្តិ ទៅលើក្រុមជ្រើសរើសទាំង១០ខាងលើ មានការសន្មត់ថា ទិន្នន័យប្រមូលបានពី អង្កេតនៅខែកុម្ភៈ និងឧសភា ២០០៧ វាឆ្លុះបញ្ចាំងពីអំឡុងពេលមុនវិបត្តិ ហើយទិន្នន័យនៅខែកុម្ភៈ និង ឧសភា ២០០៩ វាឆ្លុះបញ្ចាំងពីអំឡុងពេលក្រោយវិបត្តិ ពីព្រោះមិនអាចរកបានទិន្នន័យសំរាប់ខែកុម្ភៈ ឧសភា និង សីហា ២០០៨ ឡើយ ។ ការសិក្សានេះបានប្រើប្រាស់ simple regression technique (ordinary least squares) ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់នៃវិបត្តិ ទៅលើចំណូលប្រចាំថ្ងៃពិតចំណាយពិត និង បំណុលពិត ។ ដោយសារការសិក្សានេះ ចង់ស្វែងយល់ពីឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើកំរិតជីវភាពរបស់ពលករងាយរង

---

* អត្ថបទនេះ រៀបចំដោយ បណ្ឌិត តុង គឹមស៊ុន, លោក យៀង សុធី និង កញ្ញា ផាន់ ដាលីស ដោយមានការចូលរួមអំពី កញ្ញា ហែម មេត្តា និង អ្នកស្រី ប៉ុន ដូរីណា ។ ទស្សនៈលើកឡើងនៅក្នុងអត្ថបទនេះ គឺជារបស់អ្នកនិពន្ធផ្ទាល់ ។ អ្នកនិពន្ធសូមថ្លែងអំណរគុណ ដល់ បណ្ឌិត Hossein Jalilian, Neak Samsen, និង Tim Conway ចំពោះការជួយមតិជាច្រើនលើរបាយការណ៍ព្រាងពីដំបូង ។

គ្រោះ ដូច្នេះកត្តាផ្សេងទៀត ដូចជា អាយុ ភេទ កំរិតអប់រំ ទំហំគ្រួសារ និង បទពិសោធន៍ការងារ ត្រូវទុកឱ្យនៅថេរ បើមិនដូច្នោះទេ យើងមិនអាចដឹងពីឥទ្ធិពលនោះបានឡើយ ។ ដោយមូលហេតុនេះ វិធីសាស្ត្រដែលយកមកប្រើ គួរតែអាចផ្តល់លទ្ធផល បានត្រឹមត្រូវជាងការវិភាគបែបពណ៌នា ។ ទោះយ៉ាងណាក្តី ដោយសារមាន ព្រឹត្តិការណ៍កើតឡើងថ្មីៗដូចបានរៀបរាប់ខាងលើ វិធីសាស្ត្រក្នុងការសិក្សានេះ មិនអាចបំបែកឱ្យដាច់ពីគ្នាទេនូវ ឥទ្ធិពលនៃការប៉ះទង្គិចដែលជាករណីដោយឡែកៗ ឬជាករណីបែបសំបូរ ។

ដើម្បីបំប្លែងចំណូល ឬចំណាយប្រចាំថ្ងៃ ទៅជាតួលេខពិត យើងបានយកតួលេខចំណូល និងចំណាយប្រចាំថ្ងៃចារីក ទៅចែកនឹងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ដែលចេញផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ សំរាប់ខែកុម្ភៈ ២០០៣ រហូតដល់ វិច្ឆិកា ២០០៨ និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ដែលប៉ាន់ស្មានដោយ CDRI ផ្ទាល់សំរាប់ខែកុម្ភៈ និង ឧសភា ២០០៩ ។[១] មានការសន្មត់មួយទៀតថា អត្រាអតិផរណាប្រចាំឆ្នាំ គឺ ៦,៥% នៅខែកុម្ភៈ និង ៦,៤% នៅខែឧសភា ២០០៩ ។

## ៣. ការវិភាគផ្អែកលើការពិសោធឃើញជាក់ស្តែង

អង្កេតសំរាប់ខែឧសភា ២០០៩ បានរកឃើញថា ចំណូលប្រចាំថ្ងៃពិត របស់ពលករមិនកាត់ដេរទាំង ៩ក្រុម គឺ មានប្រហែល ៨១៥៩រៀល ឬធ្លាក់ចុះអស់ ១,៨% បើធៀបនឹង ខែឧសភា ២០០៧ ។ ប៉ុន្តែ ក្រុមអ្នករើសអេតចាយ កម្មករសំណង់មានជំនាញ កម្មករសំណង់គ្មានជំនាញ និង អ្នកស៊ីឈ្នួលធ្វើស្រែ មានចំណូលប្រចាំថ្ងៃពិត កើនឡើង ។

ការវិភាគបែបបរិមាណ បានបង្ហាញថា ចំណូលប្រចាំថ្ងៃពិត របស់ពលករទាំង ៩ក្រុមខាងលើ បានកើនឡើង ១២% បើធៀបនឹងអំឡុងពេលមុនវិបត្តិ ។ ក្នុងចំណោម ៩ក្រុមនេះ មានតែ អ្នកលីសែង អ្នករើសអេតចាយ កម្មករសំណង់គ្មានជំនាញ និង អ្នកស៊ីឈ្នួលធ្វើស្រែ ប៉ុណ្ណោះដែលមានចំណូលប្រចាំថ្ងៃកើនឡើង រីឯក្រុមដទៃទៀត គឺនៅដដែល ។ ក្នុងពេលជាមួយគ្នានេះ ចំណាយប្រចាំថ្ងៃពិតរបស់ពលករទាំង៩ក្រុម បានកើនឡើងរហូតដល់ ២៦% (កំណើនចំណាយនេះ វាធំជាង កំណើនចំណូលពិត ដល់ទៅ ១៤%) ។ កំណើននេះសមរម្យហើយ ពីព្រោះចំណែកនៃចំណាយប្រើប្រាស់នៅក្នុងប្រាក់ចំណូល កើនត្រឹមពី ៤៦% ទៅដល់ ៥១% ប៉ុណ្ណោះ ដូច្នេះនៅមានចំណូលសេសសល់សំរាប់ កែលំអសុខុមាលភាព ។ ដោយសារ ទាំងចំណូល និង ចំណាយប្រចាំថ្ងៃពិត បានកើនឡើង ហើយចំនួនភាគរយនៃពលករងាយរងគ្រោះ ដែលមានជំពាក់បំណុលគេនៅក្រោយពេលកើតវិបត្តិ ក៏មានកំរិតទាប[២] ដូច្នេះផលប៉ះពាល់នៃវិបត្តិទៅលើពលករទាំង ៩ក្រុម នៅមិនទាន់ធ្ងន់ធ្ងរប៉ុន្មានទេ ។

ដើម្បីបានដឹងពីមតិយល់ឃើញរបស់ពលករងាយរងគ្រោះ ស្តីពីចំណូលប្រចាំថ្ងៃរបស់ពួកគេ ក្រុមអង្កេតបានសុំឱ្យអ្នកឆ្លើយសម្ភាសន៍មានយោបល់ថា តើចំណូលប្រចាំថ្ងៃរបស់ខ្លួននៅឆ្នាំ២០១០ នឹងមានការខុសប្លែកពីឆ្នាំ ២០០៨ ឬយ៉ាងណា ។ តាមនេះមានកម្មករ ២១% ឆ្លើយថា ចំណូលប្រចាំថ្ងៃរបស់ខ្លួននៅឆ្នាំ២០១០ នឹងកើនច្រើនជាង ឆ្នាំ២០០៨ និង ៣៥% ទៀតឆ្លើយថា ប្រហែលនៅដដែល ឬតិចជាងមុន ហើយអ្នកនៅសល់ ៤៣% ទៀតគ្មានយោបល់ទេ ។

ចំណូលប្រចាំថ្ងៃពិតរបស់ពលករពីរក្រុមបន្ថែម (ពលករខាងទេសចរណ៍ និងពលករចំណាកស្រុក) គឺ ៩៨៦៨រៀល និង ៦០០៩រៀល ។ ពលករខាងទេសចរណ៍ មានចំណាយប្រចាំថ្ងៃជាមធ្យម ៥៧៣៥រៀល រីឯពលករចំណាកស្រុក មានត្រឹមតែ ១៥០៧រៀលប៉ុណ្ណោះ ដែលជាបរិមាណចំណាយទាបបំផុតក្នុងចំណោមពលករទាំង ១១ក្រុម ។ ពលករ ១០នាក់ ក្នុងចំណោមពលករខាងទេសចរណ៍ ២០នាក់ បានប្រាប់ថា ពួកគាត់មានជំពាក់បំណុលគេ ប៉ុន្តែមានពលករចំណាកស្រុកតែ ៤នាក់ប៉ុណ្ណោះដែលឆ្លើយដូច្នេះ ។ ពលករ ៧នាក់ ក្នុងចំណោមពលករចំណាកស្រុក ១៥នាក់ ដែលត្រលប់មកពីប្រទេសថៃវិញ បានប្រាប់ថា ពួកគាត់មិនអាចរកការងារធ្វើបានទេនៅប្រទេសថៃ ។ ការពិភាក្សា តាមក្រុមស្នូលនៅភូមិអណ្តូងត្រាច បានផ្តល់ព័ត៌មានថា អ្នកភូមិខ្លះត្រូវឱ្យកូនខានទៅរៀនខ្លះ ឬបោះបង់ការសិក្សាតែម្តង ដើម្បីអាចដើររកក្តាម ខ្យង កង្កែប និងត្រី ជាដើម នៅតាមស្រះ ឬស្រែជិតៗ ។ ម្យ៉ាងទៀត ៤២% នៃពលករខាងទេសចរណ៍ និងពលករចំណាកស្រុក រំពឹងថា នឹងមានចំណូលទាបជាងមុន ក្នុងរយៈពេលបីខែខាងមុខ ហើយមាន ៣៧% ទៀតនិយាយថា នៅឆ្នាំ២០១០ ចំណូលប្រចាំថ្ងៃរបស់ពួកគេ នឹងបានច្រើនជាងឆ្នាំ២០០៨ ។ ដូចមានបញ្ជាក់រួចមកហើយ គំរូតាងក្នុងការសិក្សានេះ មានទំហំតូច ដូច្នេះការយកលទ្ធផលរកឃើញនេះ ទៅអនុវត្តប្រើជាទូទៅនៅគ្រប់កន្លែងអាចនាំឱ្យមានការភាន់ច្រលំ ។

នៅខែឧសភា ២០០៩ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ បានធ្លាក់ចុះ ១៨% មកត្រឹម ៥៩២៩រៀល (កំរិតទាបបំផុតគិតតាំងពីខែកុម្ភៈ ២០០៣ មក) ធៀបនឹងចំណូល ៧២០៥រៀល កាលពីខែឧសភា ២០០៧ ។ ការធ្លាក់ចុះនេះ បង្កមកពីការថយចុះចំនួនម៉ោងធ្វើការតាំងពី ៦០ម៉ោង ក្នុងមួយសប្តាហ៍ នៅមុនពេលមានវិបត្តិ មកត្រឹម ៥២ម៉ោង បន្ទាប់ពីនោះមក ។ អង្កេតនៅខែកុម្ភៈ និង ឧសភា ២០០៩ បានរកឃើញថា ៤៧% នៃកម្មករកាត់ដេរ មិនមានធ្វើការម៉ោងបន្ថែមទេក្នុងរយៈ១សប្តាហ៍មុនពេលធ្វើសម្ភាសន៍ ធៀបនឹងកម្មករត្រឹមតែ ១១% ប៉ុណ្ណោះ ដែលបានរាយការណ៍ដូច្នេះ សំរាប់រយៈពេលដូចគ្នា ក្នុងឆ្នាំ២០០៧ ។ សរុបមក សកម្មភាពក្នុងវិស័យកាត់ដេរ បានរួមចុះ ដោយសារវិបត្តិសេដ្ឋកិច្ចសាកល ។

ការវិភាគបែបបរិមាណ បង្ហាញថា ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ បានធ្លាក់ចុះ ២៤% បន្ទាប់ពីវិបត្តិ ។ ក្នុងពេលជាមួយគ្នា ប្រាក់សន្សំប្រចាំថ្ងៃពិតរបស់ពួកគេ បានធ្លាក់ចុះ ២៧% រីឯ ចំណាយប្រចាំថ្ងៃ

---

១ យោងតាមវិទ្យាស្ថានជាតិស្ថិតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅទីក្រុងភ្នំពេញ សំរាប់ខែធ្នូ ២០០៨ និងខែមុនៗនោះទៀត គឺផ្អែកលើខែធ្នូ ២000 ធ្វើជាមូលដ្ឋានស្មើ ១០០ ហើយ CPI សំរាប់ខែមករា ២០០៩ និងខែក្រោយៗទៀត គឺផ្អែកលើ ខែតុលា-ធ្នូ ២០០៦ ធ្វើជាមូលដ្ឋានស្មើ ១០០ ។ ដោយសារភាពមិនស៊ីគ្នានៃឆ្នាំមូលដ្ឋាននេះ ក្រុមស្រាវជ្រាវក៏ចាំបាច់ធ្វើការប៉ាន់ស្មាននូវ CPI សំរាប់ខែកុម្ភៈ និង ឧសភា ២០០៩ ។ តម្លៃចារីកសំរាប់ពលករងាយរងគ្រោះទាំងអស់ រួមបញ្ចូលទាំង អ្នកស៊ីឈ្នួលធ្វើស្រែផងត្រូវបានធ្វើបរិវត្តផរណា ដោយប្រើ CPI របស់វិទ្យាស្ថានជាតិស្ថិតិ និង CPI ប៉ាន់ស្មានដោយ CDRI ។

២ ការធ្វើតេស្តខាងស្ថិតិសាមញ្ញមួយ បញ្ជាក់ថា ចំនួនពលករងាយរងគ្រោះដែលកំពុងជាប់បំណុលគេ មានការកើនឡើង ៨% ហើយតួលេខរបស់វាមានសារៈសំខាន់ខាងស្ថិតិ នៅកំរិត ១% ។

តារាង: ចំណូលប្រចាំថ្ងៃពិតជាមធ្យម (ជារៀល គិតតាមកំរិតថ្លៃ នៅខែវិច្ឆិកា ២០០០)

| | | អ្នកធាក់ស៊ីក្លូ | អ្នកលីសែង | អ្នកលក់បន្លែ | អ្នករើសអេតចាយ | កម្មករសំណង់មានជំនាញ | កម្មករសំណង់គ្មានជំនាញ | អ្នករត់ម៉ូតូឌុប | អ្នកបំរើភោជនីយដ្ឋាន | អ្នកស៊ីឈ្នួលធ្វើស្រែ | ពលករខាងវិស័យទេសចរណ៍ | ពលករចំណាកស្រុក | កម្មករកាត់ដេរ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០០៣ | កុម្ភៈ | 8932 | 7378 | 7039 | 3762 | 12.135 | 5983 | 11.068 | 4475 | 4053 | N/A | N/A | 8634 |
| | ឧសភា | 9281 | 7713 | 6471 | 3495 | 12.929 | 6920 | 9583 | 4233 | 3599 | N/A | N/A | 7825 |
| | សីហា | 9075 | 7007 | 6636 | 4749 | 12.332 | 7369 | 10.592 | 4374 | 4498 | N/A | N/A | 8692 |
| | វិច្ឆិកា | 9494 | 6286 | 6393 | 3774 | 16.345 | 6020 | 9671 | 4290 | 4304 | N/A | N/A | 8634 |
| ២០០៤ | កុម្ភៈ | 9168 | 8527 | 7166 | 4645 | 13.297 | 6998 | 10.864 | 4723 | 4582 | N/A | N/A | 8045 |
| | ឧសភា | 8000 | 7452 | 7241 | 4387 | 11.822 | 6505 | 8534 | 4257 | 4095 | N/A | N/A | 8066 |
| | សីហា | 7632 | 6625 | 6650 | 4770 | 13.527 | 6095 | 8950 | 4591 | 4310 | N/A | N/A | 7986 |
| | វិច្ឆិកា | 5670 | 5094 | 6755 | 4024 | 12.117 | 5967 | 8688 | 4185 | 3944 | N/A | N/A | 8098 |
| ២០០៥ | កុម្ភៈ | 8529 | 6965 | 6386 | 5382 | 14.367 | 5712 | 11.790 | 4538 | 4174 | N/A | N/A | 7983 |
| | ឧសភា | 7726 | 7067 | 8575 | 5315 | 12.304 | 8374 | 11.411 | 4295 | 4269 | N/A | N/A | 6365 |
| | សីហា | 7857 | 6004 | 5939 | 4335 | 10.274 | 6069 | 9407 | 4647 | 4291 | N/A | N/A | 7613 |
| | វិច្ឆិកា | 8229 | 6092 | 10058 | 5636 | 11.253 | 6692 | 9774 | 3893 | 4746 | N/A | N/A | 7475 |
| ២០០៦ | កុម្ភៈ | 7873 | 6520 | 6187 | 4984 | 11.750 | 5974 | 8885 | 4670 | 4790 | N/A | N/A | 7990 |
| | ឧសភា | 8546 | 7375 | 6492 | 4512 | 9834 | 6407 | 8791 | 4243 | 5577 | N/A | N/A | 6814 |
| | សីហា | 6064 | 5239 | 5197 | 4266 | 9467 | 6029 | 6744 | 4292 | 5111 | N/A | N/A | 8029 |
| | វិច្ឆិកា | 7394 | 7046 | 7682 | 3903 | 10.215 | 5263 | 8386 | 4443 | 5747 | N/A | N/A | 7762 |
| ២០០៧ | កុម្ភៈ | 6535 | 7996 | 6514 | 4530 | 10.355 | 5094 | 9144 | 4078 | 5011 | N/A | N/A | 8211 |
| | ឧសភា | 9246 | 9798 | 8949 | 5533 | 11.892 | 6075 | 12.887 | 5151 | 5236 | N/A | N/A | 7205 |
| | សីហា | 7128 | 7705 | 9116 | 6063 | 11.410 | 5901 | 8979 | 4193 | 5578 | N/A | N/A | 7828 |
| | វិច្ឆិកា | 9393 | 8853 | 8303 | 5560 | 10.957 | 7550 | 11.525 | 4508 | 6239 | N/A | N/A | 7029 |
| ២០០៨ | កុម្ភៈ | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A |
| | ឧសភា | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A |
| | សីហា | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A |
| | វិច្ឆិកា | 12.628 | 9005 | 9926 | 4652 | 12.710 | 8779 | 15.691 | 4327 | 8697 | N/A | N/A | 6554 |
| ២០០៩ | កុម្ភៈ | 8506 | 10.442 | 7589 | 5153 | 11.732 | 6095 | 11.613 | 4268 | 7021 | N/A | N/A | 6732 |
| | ឧសភា | 7884 | 9144 | 8652 | 5881 | 12.129 | 8823 | 10.765 | 3851 | 6315 | 9868 | 6009 | 5929 |
| | សីហា | | | | | | | | | | | | |
| | វិច្ឆិកា | | | | | | | | | | | | |

ប្រភព: ទិន្នន័យបានពីអង្កេតរបស់ CDRI

ពិតវិញ កើនឡើង ៧% (តួលេខទាំង២នេះ មានសារៈសំខាន់ខាងស្ថិតិ នៅកំរិត ១%) ។ ទាំងចំណូលប្រចាំថ្ងៃពិត និងប្រាក់សន្សំ នឹងបន្តធ្លាក់ចុះ ប្រសិនបើវិបត្តិនៅតែកើតមានជាបន្ត ។ កាលពីខែឧសភា ២០០៩ ក្នុងចំណោមកម្មករកាត់ដេរ ១២០នាក់ ដែលបានឆ្លើយសម្ភាសន៍ មានតែ ២១% ប៉ុណ្ណោះដែលរំពឹងថា ចំណូលរបស់ខ្លួននៅឆ្នាំ២០១០ នឹងមានបរិមាណច្រើនជាងឆ្នាំ២០០៨ ប៉ុន្តែមាន ៤២% បានប្រាប់ថា ប្រាក់ចំណូលរបស់ខ្លួនអាចនឹងនៅដដែល ឬធ្លាក់ទាបជាងនេះ ។

## ៤. សេចក្តីសន្និដ្ឋាន

អត្ថបទនេះមានគោលដៅធ្វើការវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើពលករងាយរងគ្រោះ នៅប្រទេសកម្ពុជា ។ ចាប់តាំងពីដើមឆ្នាំ២០០៩ នេះមក ការសិក្សាវាយតម្លៃរហ័សមួយចំនួន (Kang et al. 2009; Jalilian et al. 2009) ពីផលប៉ះពាល់ម៉ាក្រូសេដ្ឋកិច្ច បង្កពីវិបត្តិ បានបង្ហាញថា ផលប៉ះពាល់អាចកាន់តែធ្ងន់ធ្ងរ ដោយសារការរួមចុះនៃវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ។ ការសិក្សានេះបានរកឃើញថា វិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរបំផុតទៅលើកម្មករកាត់ដេរ ព្រោះវិស័យកាត់ដេរពឹងផ្អែកខ្លាំងលើតំរូវការពីសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ប៉ុន្តែប៉ះពាល់មិនសូវខ្លាំងប៉ុន្មានទេ ទៅលើពលករងាយរងគ្រោះ ៩ក្រុមផ្សេងទៀត ។ ចំពោះពលករខាងទេសចរណ៍ និងពលករចំណាកស្រុក ការវិភាគបែបគុណភាព បានបង្ហាញថាជីវភាពរបស់ពួកគេកាន់តែយ៉ាប់យ៉ឺនខ្លាំងណាស់ ។ ដើម្បីឆ្លើយតបនឹងវិបត្តិសេដ្ឋកិច្ចសាកលនេះ រដ្ឋាភិបាលកម្ពុជាបានអនុវត្តគោលនយោបាយជាច្រើនសំរាប់វិស័យកាត់ដេរ ជាអាទិ ការផ្អាកការប្រមូលអាករលើផលរបរប្រចាំខែ ១% លើការចំណាយរបស់រោងចក្រ ការកាត់បន្ថយ ១០% លើប្រាក់កំរៃគ្រប់គ្រងការនាំចេញ និងចំណាយផ្សេងទៀត និង ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី ដល់ពលករដែលត្រូវបញ្ឈប់ពីការងារ និងពលករគ្មានការងារធ្វើ (សំរាប់ ព័ត៌មានលំអិត សូមមើលអត្ថបទរបស់ Jalilian et al. 2009) ។ ការប្រមើលមើលពីចំណូលប្រចាំថ្ងៃនៅឆ្នាំ២០១០ ក៏នៅឃើញអាប់អួរដែរ ៕

### ឯកសារយោង


Jalilian, Hossein et al. (April 2009), The Global Financial Crisis and Developing Countries: Cambodia (Phnom Penh: CDRI )

Kang Chandararot et al. (January 2009), Rapid Assessment on the Impact of the Financial Crisis in Cambodia (Phnom Penh: CIDS)


*តពីទំព័រ ១* **ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច ...**

និងចំនួនការងារក្នុងវិស័យនេះ ។ ការធ្លាក់ចុះនេះ ជាបន្តមកទៀតក៏បានប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលទៅលើជីវភាពរបស់ពលករក្នុងវិស័យកាត់ដេរ និងអ្នកទទួលការផ្គត់ផ្គង់ពីពលករទាំងនេះ ។ គួបផ្សំនឹងការថយចុះចំនួនអ្នកទេសចរចូល និងការធ្លាក់ចុះសកម្មភាពសាងសង់ ដែលបង្កមួយចំណែកដោយការធ្លាក់ចុះ FDI ក៏ដូចជាផលប៉ះពាល់អាក្រក់នៃការធ្លាក់ចុះសេដ្ឋកិច្ចនៅតាមប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗផង សុខុមាលភាព និងជីវភាពរបស់ជនងាយរងគ្រោះ និងប្រជាជនក្រីក្រនៅកម្ពុជា បានទទួលការប៉ះពាល់ធ្ងន់ធ្ងរ ។

វិបត្តិហិរញ្ញវត្ថុសាកល និងវិបត្តិហិរញ្ញវត្ថុអាស៊ីនៅឆ្នាំ១៩៩៧ បានគូសរំលេចពីសារៈសំខាន់នៃការត្រួតពិនិត្យ និងបទបញ្ញត្តិគ្រប់គ្រងវិស័យហិរញ្ញវត្ថុ ។ ទទឹមគ្នានេះ វាក៏បានចោទជាសំណួរទៅលើវិធីសាស្ត្រ ដែលប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបានអនុម័តប្រើ ដោយមានការជំរុញពីស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដូចជា មូលនិធិរូបិយវត្ថុអន្តជាតិ ធនាគារពិភពលោកជាដើម គឺបានព្យាយាមចំលងយកគំរូអភិវឌ្ឍទីផ្សារមូលធន និងហិរញ្ញវត្ថុនៅបណ្តាប្រទេសមានការអភិវឌ្ឍន៍ជឿនលឿន ដោយពុំទាន់ទាំងបំពេញបាននូវលក្ខខណ្ឌចាំបាច់ផ្សេងៗនៅឡើយ ។ ឧទាហរណ៍ ប្រទេសទាំងនោះមិនបានព្យាយាមអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយសាមញ្ញ ស្របតាមតំរូវការក្នុងស្រុកទេ ប៉ុន្តែទៅពឹងផ្អែកយ៉ាងខ្លាំងលើបណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលមានអត្រាបំណុលកំរិតខ្ពស់ ហើយខំប្រឹងបង្កើតទីផ្សារមូលធនបែបទំនើបស្មុគស្មាញ ដូចជា ផ្សារហ៊ុន ជាដើម ដោយមិនបានពិចារណាល្អិតល្អន់ពីតំរូវការអភិវឌ្ឍន៍ក្នុងស្រុក ព្រមទាំងកត្តាចំណេញខាតជាប់ទាក់ទិននានា ។ ប្រទេសកម្ពុជាកំពុងត្រូវការជាខ្លាំងនូវ ស្ថាប័នហិរញ្ញវត្ថុសម្រាប់ដំណើរការក្នុងស្រុក ដែលអាចសំរបសំរួលរវាងអ្នកសន្សំប្រាក់ និងអ្នកខ្ចីប្រាក់ ជាពិសេសនៅតាមតំបន់ជនបទ ដោយមិនមានពាក់ព័ន្ធនិងអន្តរកម្មហិរញ្ញវត្ថុបែបទំនើប និងស្មុគស្មាញនោះទេ ។ ក្នុងដំណាក់កាលអភិវឌ្ឍន៍សព្វថ្ងៃនេះ គេមិនច្បាស់ទេថាប្រទេសកម្ពុជាអាចបានចំណេញអ្វីខ្លះពីការបង្កើតទីផ្សារភាគហ៊ុនតាមការគ្រោងទុកនោះទេ ។ ពិតហើយ ទីផ្សារភាគហ៊ុន និងទីផ្សារមូលធនផ្សេងទៀតនឹងមានតំរូវការក្នុងរយៈពេលវែង ប៉ុន្តែតំរូវការក្នុងអនាគតដ៏ខ្លីខាងមុខ គឺជាសំនួរមួយយ៉ាងធំ ។

ក្នុងពេលថ្មីៗនេះ វិទ្យាស្ថាន CDRI បានអនុវត្តឱ្យ ធនាគារពិភពលោកនូវការវាយតំលៃរហ័សមួយស្តីពីផលប៉ះពាល់នៃវិបត្តិទៅលើជីវភាពរបស់ជនងាយរងគ្រោះ និងប្រជាជនក្រីក្រនៅកម្ពុជា ។ អត្ថបទនានាដែលចុះផ្សាយក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា លេខនេះ បានផ្អែកលើប្រធានបទមួយចំនួននៃការសិក្សាស្រាវជ្រាវដែលធ្វើឡើង នៅខែឧសភា ២០០៩ ។ ដូចការរំពឹងទុក លទ្ធផលរកឃើញមួយចំនួនដែលផ្អែកលើការវិភាគបែបបរិមាណ មិនបានបញ្ជាក់គាំទ្រដល់លទ្ធផលរកឃើញតាមការវិភាគបែបគុណភាព ជាពិសេសលទ្ធផលបានមកពីការពិភាក្សាតាមក្រុមស្នូលនោះទេ ។ ចំណុចនេះបានជួយបង្ហាញពី ដែនកំណត់នៃការវាយតម្លៃរហ័សដែលមានរយៈពេល និងធនធានមានកំណត់ ព្រមទាំងពីតំរូវការធ្វើអង្កេតលំអិតបន្ថែមទៀត ៕